ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៣២/១៩ - ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ត្រៀល
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អាន វីរៈ**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **អាំង អេងថុង**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ត្រៀល**
អាសយដ្ឋាន ៖ ភូមិត្រពាំងឈើនាង ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១៧ ៧៦៧ ៣៨៥ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖
១-លោក កុល វុត្ថា នាយកធនធានមនុស្ស
២-លោក អ៊ុំ វិសាល មន្ត្រីGMAC

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ត្រៀល**
អាសយដ្ឋាន ៖ ភូមិត្រពាំងឈើនាង ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០៩២ ៤៦៥ ១៧២ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖ អវត្តមាន។

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ក្រុមហ៊ុនត្រូវសង់ទារកដ្ឋាន(បន្ទប់បំបៅកូន) ក្នុងក្រុមហ៊ុន ជូនកម្មករ កម្មការិនី (បើមិនមានស្នើសុំលុយទឹកដោះគោ ចំនួន ២៥ ដុល្លារ អាមេរិក ក្នុង ១ ខែ រយៈពេល ១៨ ខែ)។

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

២- នៅពេលកម្មករសុំច្បាប់មានធុរៈផ្សេងៗ សូមឲ្យក្រុមហ៊ុនផ្តល់ភាពងាយស្រួល ជូនកម្មករ កម្មការិនី កុំរើសអើង។

៣- ស្នើសុំក្រុមហ៊ុនផ្តល់លុយបាយថ្ងៃត្រង់ ចំនួន ៤០០០ រៀល ជូនកម្មករ កម្មការិនី និងបើកក្នុង ១ សប្តាហ៍ម្តង រៀងរាល់ថ្ងៃសៅរ៍។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ (អាណត្តិទី១៦)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្ទ្រៀល លេខ៥៨៦/១៩ ក.ប/កណ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃចន្ទ ៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់សហជីពរក្សាសិទ្ធិកម្មករកម្ពុជានៃក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្ទ្រៀល ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៩ លើការទាមទារលក្ខខណ្ឌការងារ និងអត្ថប្រយោជន៍ ចំនួន ៤ ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ និងបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកធ្វើការផ្សះផ្សានៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩ ប៉ុន្តែ ភាគីទាំងពីរបានឯកភាពលើកពេលផ្សះផ្សា ចំនួន ១០ ថ្ងៃ គិតពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩ ដោយផ្អែកលើកិច្ចព្រមព្រៀងចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩។ រហូតដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលលិខិតបដិសេធមិនចូលរួមដោះស្រាយការទាមទាររបស់សហជីពរក្សាសិទ្ធិកម្មករកម្ពុជាទេ។

នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៩ មន្ត្រីជំនាញនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានធ្វើការផ្សះផ្សាការទាមទារ ចំនួន ៤ ចំណុចនេះ ដោយភាគីនិយោជកមិនបានចូលរួមផ្សះផ្សាទេ។ ភាគី

កម្មករនិយោជិតឯកភាពដកចំណុចវិវាទទី៤ ចេញពីការទាមទារ ដោយសារចំណុចវិវាទនេះ បានដោះស្រាយរួចរាល់នៅក្នុងក្រុមហ៊ុនហើយ។

ចំណុចមិនសះជា ដែលនៅសល់ចំនួន ៣ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល លេខ ៥៨៦/១៩ ក.ប/កណ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីកម្មករនិយោជិត និងភាគីនិយោជកមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ៣ ចំណុចនេះ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល តាមរយៈលិខិតអញ្ជើញលេខ ២១៧ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ទៅភាគីនិយោជក និងលិខិតអញ្ជើញលេខ ២១៨ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ទៅភាគីកម្មករនិយោជិត។ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ដដែល មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានទាក់ទងតាមទូរស័ព្ទបន្ថែមទៀតទៅកាន់ភាគីកម្មករនិយោជិតតំណាងដោយលោក សាន ណារ៉ុ ជាប្រធានសហជីព និងលោក កង វិសាល ជាអនុប្រធាននៃសហជីពរក្សាសិទ្ធិកម្មករខ្មែរ និងតំណាងភាគីនិយោជក អំពីការអញ្ជើញចូលរួមសវនាការ ហើយភាគីកម្មករនិយោជិត និងភាគីនិយោជកបានទទួលដឹងព័ត៌មានអំពីថ្ងៃសវនាការនេះផងដែរ។ ភាគីនិយោជកមានវត្តមាននៅថ្ងៃសវនការ ប៉ុន្តែ ភាគីកម្មករនិយោជិត មិនមានវត្តមាននៅថ្ងៃសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។

នៅថ្ងៃសវនាការ មុនម៉ោងកំណត់សវនាការ មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទូរស័ព្ទទៅ លោក កង វិសាល ជាអនុប្រធានសហជីពរក្សាសិទ្ធិកម្មករខ្មែរ សួរនាំអំពីការធ្វើដំណើរមកចូលរួមសវនាការ ថាតើពួកគាត់អញ្ជើញមកដល់ណាហើយ។ លោក កង វិសាល បានប្រាប់មកមន្ត្រីលេខាធិការដ្ឋានថាមិនបានមកចូលរួមសវនការទេ ដោយសារកំពុងជាប់រវល់ចូលរួមមង្គលការរបស់បងប្អូន ហើយគាត់បានប្រាប់មន្ត្រីលេខាធិការដ្ឋានឲ្យទាក់ទងទៅប្រធានសហជីពវិញ គឺលោក សាន ណារ៉ុ។ មន្ត្រីលេខាធិការដ្ឋាន បានទាក់ទងទៅលោក សាន ណារ៉ុ ហើយគាត់បានប្រាប់ថា គាត់មិនចាំថ្ងៃសវនាការទេ ចាំគាត់ទាក់ទងទៅក្រុមការងាររបស់គាត់។ មន្ត្រីសហព័ន្ធរក្សាសិទ្ធិកម្មករខ្មែរ បានប្រាប់មកមន្ត្រីលេខាធិការដ្ឋានថា ពួកគាត់មិនអាចចូលរួមសវនាការអាជ្ញាកណ្តាលបានទេ ហើយបានស្នើសុំឲ្យមានការលើកពេលសវនាការអាជ្ញាកណ្តាល ពីព្រោះពួកគាត់មិនអាចធ្វើដំណើរមកបាន។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- សារណាការពារ ចុះថ្ងៃចន្ទ ៣កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណាការពារក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល លេខ ២៥៤៦ ពណ.ចបព ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៣។

៣- លក្ខន្តិកៈក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល បានតម្កល់ទុកនៅនាយកដ្ឋាននីតិវិធី និងច្បាប់វិនិយោគ លេខ ១៥៣៨/០៥ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨។

៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល ចុះទិដ្ឋាការលេខ ០០៣/០៧ កបវ/កណ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧ និងបានឃើញ និងបញ្ជាក់ថាត្រឹមត្រូវ ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល លេខ ៥៨៦/១៩ ក.ប/កណ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល លេខ ០១០/១៩ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ របស់មន្ទីរការងារខេត្តកណ្តាល។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២១៧ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៨ កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២១៨ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៨កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩។

## អង្គហេតុ

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹងមិនបានចូលរួមនីតិវិធីក្នុងសវនាការ។

## ហេតុផលនៃសេចក្តីសម្រេច

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរឬទេ ក្នុងករណីអវត្តមានរបស់ភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹង ?

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រការ ២១ ចែងថា ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាច*

*បន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់* ” ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញា-កណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីពិតទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"*។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសតិ៍, លេខ ២៧/០៧-អ៊ឹម និង រ៉េ ៣, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១១/១១-ជូន តិចថាយល៍, លេខ ១៣១/១២-ម៉ាស្ទ័រ & ប្រ៉ែង, លេខ ១០៨/១៣-អាត់តូ និង លេខ ៣៣២/ ១៤-ធី & ខេ ហ្គាមេន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបីដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាល គឺ "លក្ខខណ្ឌទី១៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ, លក្ខខណ្ឌទី២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងលក្ខខណ្ឌទី៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន” ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះត្រូវបានបំពេញដែរ ឬទេ ?

**លក្ខខណ្ឌទី ១ ៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ**

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីកម្មករនិយោជិត ដើម្បីឲ្យមកចូលរួមក្នុងសវនាការអាជ្ញាកណ្តាលយ៉ាងត្រឹមត្រូវ តាមរយៈលិខិតអញ្ជើញលេខ ២១៨ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩។ នៅក្នុងលិខិតនោះ បានបញ្ជាក់យ៉ាងច្បាស់លាស់អំពីកាលបរិច្ឆេទនៃសវនាការ គឺនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩។ បន្ថែមពីលើលិខិត នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានទាក់ទងតាមទូរស័ព្ទទៅកាន់ភាគីកម្មករនិយោជិត មានលោក កង វិសាល ជាអនុប្រធានសហជីពរក្សាសិទ្ធិកម្មករខ្មែរ និង លោក សាន ណារ៉ី ជាប្រធានសហជីពរក្សាសិទ្ធិកម្មករខ្មែរ ដើម្បីបញ្ជាក់អំពីការអញ្ជើញចូលរួមសវនាការ ហើយភាគីកម្មករនិយោជិតក៏បានទទួលដឹងឮ នូវព័ត៌មានអំពីសវនាការនេះផងដែរ។ នៅថ្ងៃសវនាការ គឺនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ មុនម៉ោងកំណត់សវនាការមន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទូរស័ព្ទទៅកាន់ លោក កង វិសាល ជាអនុប្រធានសហជីពរក្សាសិទ្ធិកម្មករខ្មែរ សួរនាំអំពីការធ្វើដំណើរមកចូលរួមសវនាការ ថាតើពួកគាត់អញ្ជើញមកដល់ណាហើយ។ ប៉ុន្តែ លោក កង វិសាល បានប្រាប់ថាមិនបានមកចូលរួមសវនការទេ ដោយសារកំពុងជាប់រវល់ចូលរួមមង្គលការរបស់បងប្អូន ហើយគាត់បានប្រាប់ឲ្យមន្ត្រីលេខាធិការដ្ឋានទាក់ទងទៅប្រធានសហជីពវិញ គឺលោក សាន ណារ៉ី។ មន្ត្រីលេខា-ធិការដ្ឋានបានទាក់ទងទៅលោក សាន ណារ៉ី ហើយគាត់បានប្រាប់ថា គាត់មិនចាំថ្ងៃសវនាការទេ ចាំគាត់ទាក់ទងទៅក្រុមការងាររបស់គាត់។ មន្ត្រីសហព័ន្ធរក្សាសិទ្ធិកម្មករខ្មែរ បានប្រាប់មកមន្ត្រីលេខាធិការដ្ឋានថា ពួកគាត់មិនអាចចូលរួមសវនាការអាជ្ញាកណ្តាលបានទេ និងបានស្នើសុំឲ្យមានការពន្យារពេលសវនាការអាជ្ញាកណ្តាល ពីព្រោះ ពួកគាត់មិនអាចធ្វើដំណើរមកបាន។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីដើមបណ្តឹងពិតជាទទួលបានការអញ្ជើញត្រឹមត្រូវ ពីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ឲ្យចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិតប្រាកដមែន។ ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល " នៅក្នុងប្រការ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញា-កណ្តាល រហូតចប់សព្វគ្រប់។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឲ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

ក្នុងករណីនេះ ភាគីកម្មករនិយោជិត មិនមានវត្តមាននៅក្នុងសវនាការទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដើមបណ្តឹងមិនមានវត្តមាននៅក្នុងសវនាការ ហើយក៏មិនបានចូលរួមគ្រប់ដំណាក់កាលទាំងបួនខាងលើនេះ។ ហេតុនេះ ភាគីដើមបណ្តឹងមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល តាមខ្លឹមសារប្រការ២១ នៃប្រកាសលេខ ០៩៩ លើនេះទេ។ ដូចនេះ លក្ខខណ្ឌទី២ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតមិនមានវត្តមាននៅក្នុងសវនាការទេ ដោយបានបញ្ជាក់តាមទូរសព្ទជាមួយមន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ពួកគាត់មិនអាចចូលរួមសវនាការអាជ្ញា-កណ្តាលបាននោះទេ និងបានស្នើសុំឲ្យមានការលើកពេលសវនាការ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការមិនមានវត្តមាននៅថ្ងៃសវនាការ ដោយបញ្ជាក់ថា មិនអាចធ្វើដំណើរមកចូលរួមសវនាការអាជ្ញាកណ្តាលបាន ដោយមូលហេតុជាប់រវល់ចូលរួមមង្គលការបងប្អូន និងមិនដឹងថ្ងៃសវនាការ ហើយបានស្នើសុំឲ្យមានការលើកពេលសវនការ គឺមិនអាចចាត់ទុកថា មានមូលហេតុត្រឹមត្រូវនោះទេ។ ម្យ៉ាងវិញទៀត ប្រសិនបើកម្មករនិយោជិតពិតជាមានបំណងក្នុងការពន្យារពេលសវនាការអាជ្ញា-កណ្តាលមែន ភាគីកម្មករនិយោជិតគួរតែទាក់ទងមកមន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលជាមុន មិនមែនរង់ចាំទាល់តែមន្ត្រីលេខាធិការដ្ឋានទាក់ទងទៅសួរ ទើបពួកគាត់ផ្តល់ព័ត៌មានថា ភាគីកម្មករនិយោជិតមានបំណងពន្យារសវនាការអាជ្ញាកណ្តាលនោះឡើយ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ដើមបណ្តឹងមិនមានហេតុផលត្រឹមត្រូវ សម្រាប់ការមិនមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដូច្នេះ លក្ខខណ្ឌទី៣ ត្រូវបានបំពេញ។

សរុបសេចក្តីមក លក្ខខណ្ឌទាំងបីដែលមានចែងក្នុងប្រការ២១ នៃប្រកាសលេខ ០៩៩ ខាងលើ ត្រូវបានបំពេញ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កាតព្វកិច្ចរបស់ភាគីដើមបណ្តឹង និងភាគីចុងចម្លើយនៃសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺត្រូវមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបកស្រាយបង្ហាញដោយផ្ទាល់មាត់ នូវការអះអាងរបស់ខ្លួន ក៏ដូចជាផ្តល់ជូននូវឯកសារ និងព័ត៌មានចាំបាច់

THE ARBITRATION COUNCIL

ផ្សេងៗដែលពាក់ព័ន្ធនឹងចំណុចវិវាទ សម្រាប់ឲ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងសម្រេចសេចក្តី។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងទាមទាររបស់ខ្លួន។ ចំណែកឯភាគីចុងចម្លើយមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះបន្ទុករបស់ខ្លួនពីការទាមទារពីសំណាក់ដើមបណ្តឹង ដែលកាតព្វកិច្ចនេះ ជាទូទៅ នឹងត្រូវកើតឡើងក្រោយពេលដែលដើមបណ្តឹងបានបំពេញកាតព្វកិច្ចរបស់ខ្លួនជាមុនសិន។

ក្នុងសំណុំរឿងនេះ ភាគីដើមបណ្តឹងមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបំពេញនូវកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ លើសពីនេះ ភាគីដើមបណ្តឹងក៏មិនមានមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា ភាគីដើមបណ្តឹងបានបោះបង់ចោលការទាមទាររបស់ខ្លួនហើយ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនចាំបាច់បន្តដំណើរការអាជ្ញាកណ្តាលនោះទេ។

ហេតុនេះ ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា ដើមបណ្តឹងបានបោះបង់ចោលពាក្យបណ្តឹងរបស់ខ្លួន។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។

ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៣២/១៩-ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល នេះ។

## សម្រេច

បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ០៣២/១៩-ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ។

**ហត្ថលេខាក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក
ឈ្មោះ ៖ **អ៊ីង សុទ្ធី**
ហត្ថលេខា: ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត
ឈ្មោះ ៖ **អាន វីរៈ**
ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល
ឈ្មោះ ៖ **អាំង អេងថុង**
ហត្ថលេខា: ------------------------------------